ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

ក ស វ



## Work Activities

ប្រចាំខែធ្នូ ឆ្នាំ២០១៧



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| - សេចក្តីព្រាងយុទ្ធសាស្ត្រជាតិរេដបូក ២០១៧-២០២៦ | ១-២ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ( ក្រុម RIA ) | |
| ១- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់នាយទាហាននៃកងយោធពលខេមរភូមិន្ទ | ៣-៥ |
| ២- សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងកិច្ចពិគ្រោះយោបល់លើសំណើបញ្ញត្តិកម្មពាក់ព័ន្ធក្នុងវិស័យអប់រំ | ៦-៧ |
| III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ៨-១៥ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ឆាយលី** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១៧ | ១៦-១៩ |

# សេចក្តីព្រាងយុទ្ធសាស្រ្តជាតិ

## រេដបូក ២០១៧-២០២៦

កាលពីថ្ងៃទី១៤ និងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្រ្តីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងយុទ្ធសាស្រ្តជាតិរេដបូក ២០១៧-២០២៦** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្រ្តីនៃក.ស.វ. សមាជិកនិងមន្រ្តីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្រ្តី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្រ្តីជំនាញទីស្តីការគណៈរដ្ឋមន្រ្តី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រាជរដ្ឋាភិបាលកម្ពុជាផ្តល់ការគាំទ្រយ៉ាងខ្លាំងក្លាដល់ការរៀបចំ និងការអនុវត្តយុទ្ធសាស្រ្តរេដបូកជាតិ ហើយបានចាត់ទុករេដបូកជាជម្រើសក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ។ លទ្ធផលទទួលបានពីការអនុវត្តគោលនយោបាយ និងវិធានការរេដបូកប្រកបដោយប្រសិទ្ធភាព នឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ការផ្លាស់ប្តូរឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាបានធ្វើសមាហរណកម្មបញ្ចូលរេដបូកជាផ្នែកមួយទៅក្នុងគោលនយោបាយយុទ្ធសាស្រ្ត និងកម្មវិធីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ខ្លួនផងដែរ។

កម្មវិធីរេដបូក គឺបានអនុលោមតាមសេចក្តីសម្រេចនានារបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសអាធាតុ។ ការអនុវត្តរេដបូកនៅកម្ពុជា ចែកចេញជាបីដំណាក់កាលជាបន្តបន្ទាប់ រួមមាន ដំណាក់កាលត្រៀមលក្ខណៈ ដំណាក់កាលអនុវត្ត និងដំណាក់កាលទូទាត់ ផ្អែកតាមលទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ និងការប្រើប្រាស់ដី។ កម្ពុជាបានចាប់ផ្តើមអនុវត្តដំណាក់កាលត្រៀបលក្ខណៈរេដបូកក្នុងឆ្នាំ២០១២។ នៅក្នុងដំណាក់កាលនេះ កម្ពុជាសម្រេចបានវឌ្ឍនភាពជាច្រើនស្របទៅតាមចំណុចដៅនានា ដែលឆ្លើយតបទៅតាមតម្រូវការរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ កម្រិតយោងព្រៃឈើរបស់កម្ពុជាត្រូវបានរៀបចំរួចរាល់ និងបានដាក់ជូនទៅអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុកាលពីចុងឆ្នាំ២០១៦។ យុទ្ធសាស្រ្តរេដបូកជាតិ និងប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិក៏ត្រូវបានរៀបចំបញ្ចប់ផងដែរ ហើយការវិភាគលើគោលនយោបាយ រួមទាំងការពិគ្រោះយោបល់សំខាន់ៗជាច្រើនក៏បានធ្វើឡើង ដើម្បីរៀបចំតាក់តែង និងបង្កើតប្រព័ន្ធព័ត៌មានធានាសុវត្ថិភាពរេដបូក។

**ចក្ខុវិស័យ:** យុទ្ធសាស្ត្រជាតិរេដបូក ចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាតិ និងពិភពលោក តាមរយៈការធ្វើឲ្យប្រសើរឡើងនូវការងារគ្រប់គ្រងធនធានធម្មជាតិ និងដីព្រៃឈើ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**បេសកកម្ម:** ពង្រឹងមុខងារ និងសមត្ថភាពស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវការងារគ្រប់គ្រងធនធានធម្មជាតិ និងដីព្រៃឈើ និងការអភិរក្សជីវៈចម្រុះ។

**គោលបំណង:** កាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ លើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

នៅក្នុងដំណាក់កាលដំបូងនេះ យុទ្ធសាស្ត្ររេដបូកជាតិ នឹងផ្តោតការយកចិត្តទុកដាក់ដោះស្រាយបុព្វហេតុនៃការបាត់បង់ព្រៃឈើ និងការកសាងសមត្ថភាពជាបណ្តើរៗ ដើម្បីដោះបុព្វហេតុនៃការរេចរឹលព្រៃឈើជាក្រោយ។ បន្ទាប់មក កម្ពុជានឹងឈានទៅអនុវត្តរេដបូកកម្រិតជាតិស្របតាមយន្តការនៃការទូទាត់ផ្អែកលើលទ្ធផលនៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ កម្ពុជាក៏នឹងពិចារណាផងដែរលើការអនុវត្តគម្រោងរេដបូកនានានៅថ្នាក់ក្រោមជាតិ និងផ្អែកលើយន្តការទីផ្សារការបូនស្ម័គ្រចិត្ត ដែលមានលក្ខណៈវិនិច្ឆ័យជាក់លាក់ដោយឡែក។

ដើម្បីសម្រេច ចក្ខុវិស័យ បេសកកម្ម និងគោលបំណងទាំងនេះ យុទ្ធសាស្ត្ររេដបូកជាតិ បានកំណត់ទិសដៅជាយុទ្ធសាស្ត្រចំនួន៣រួមមាន (១) កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការពិនិត្យតាមដានធនធានព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ (២) ពង្រឹងការអនុវត្តសកម្មភាពគ្រប់គ្រងប្រកបដោយនិរន្តរភាព និង(៣) បញ្ជ្រៀបវិធីសាស្ត្រកាត់បន្ថយការបាត់បង់ព្រៃឈើ បង្កើនសមត្ថភាព និងលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធ។

សេចក្តីព្រាងស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារមាន ៤ ជំពូក និង ៩ មាត្រា[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងយុទ្ធសាស្ត្រជាតិរេដបូក ២០១៧-២០២៦។

# ១- សិក្ខាសាលា
# ស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់នាយទាហាននៃកងយោធពលខេមរភូមិន្ទ
# សណ្ឋាគារសុខា ភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧




ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារRIA របស់ក្រសួងការពារជាតិ សហការជាមួយក្រុមការងារRIAរបស់ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់នាយទាហាននៃកងយោធពលខេមរភូមិន្ទ ក្រោមជំនួយបច្ចេកទេសរបស់ADB លេខ៨៨៣៤។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** នាយរងសេនាធិការចម្រុះ មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវៈកម្ម និងឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានផ្តល់កិត្តិយសធ្វើជាអធិបតីភាពក្នុងអង្គសិក្ខា។ ក្នុងដំណើរការសិក្ខាសាលារយៈពេលមួយថ្ងៃនេះ មានវាគ្មិនចំនួន ៣ រូប គឺ ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានធ្វើបទបង្ហាញអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា បន្ទាប់មកលោក **ឃឹម ចំណាប់ភក្តី** អនុប្រធាននាយកដ្ឋាននីតិកម្ម និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងពាណិជ្ជកម្ម បានធ្វើបទបង្ហាញអំពីការវាយតម្លៃបឋមលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសអន្តរក្រសួង





ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** ឯកឧត្តម **ឃឹម ណុលសន**

ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា និងលោក **នាង ម៉ៅ** អគ្គនាយករង និងជាប្រធានក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានធ្វើបទបង្ហាញអំពីការវាយតម្លៃបឋមលើផលប៉ះពាល់ នៃសេចក្តីព្រាងប្រកាសស្តីពីលក្ខណ្ឌនិងនីតិវិធីនៃការផ្តល់ការកែប្រែ ការព្យួរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ដែលមានសិក្ខាកាមចូលរួមចំនួន ២៣០នាក់។







ឯកឧត្តម **ប៊ិច សុខា** លោក **ឃឹម ចំណាប់ភក្តី** លោក **នាង ម៉ៅ**

ក្នុងពិធីបើកអង្គសិក្ខាសាលានេះ ឯកឧត្តម **ឃឹម ណុលសន** បានមានមតិស្វាគមន៍ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** ថ្លែងសន្ទរកថាបើក បានបញ្ជាក់ថា ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជា ទទួលបានការរីកចម្រើនលូតលាស់ និងកំពុងអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់វិស័យ ហើយផ្នែកសំខាន់មួយគឺការកំណែទម្រង់លើលិខិតបទដ្ឋានគតិយុត្តឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ នៅក្នុងការរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ បទដ្ឋានគតិយុត្តផ្សេងៗគាំទ្រដល់សេដ្ឋកិច្ចសង្គមឲ្យទាន់សម័យទំនើប ក្នុងសកលភាវូបនីយកម្មទៀតផង។ ពិតណាស់លិខិតបទដ្ឋានក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិមិនពាក់ព័ន្ធដោយផ្ទាល់ដល់សេដ្ឋកិច្ចជាតិក៏ដោយ ក៏ប៉ុន្តែបានចូលរួមយ៉ាងសំខាន់បំផុតក្នុងការការពារមាតុភូមិឲ្យមានសន្តិភាព សុវត្ថិភាព ស្ថេរភាពជូនសង្គមជាតិទាំងមូល ទើបអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរីកចម្រើនដល់ពេលបច្ចុប្បន្ន នឹងបន្តភាពរុងរឿងទៅអនាគតទៀត។

សិក្ខាសាលាផ្តល់ឱកាសក្នុងស្វែងយល់ពីវិធីសាស្រ្ត RIA ដែលបាននឹងកំពុងអនុវត្តនៅកម្ពុជា និងអត្ថប្រយោជន៍នៃការប្រើប្រាស់ RIA ក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត។ RIA គឺជាទម្លាប់អនុវត្តល្អសម្រាប់

ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើនដែលជាសមាជិកនៃOECD(អង្គការអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ) និងម្យ៉ាងទៀតនៅប្រទេស ASEAN ដូចជាវៀតណាម ឡាវ ថៃ ហ្វីលីពិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ទទួលស្គាល់យ៉ាងទូលំទូលាយថា៖



- លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច;
- អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យផ្អែកលើការ អនុវត្តជាក់ស្តែង
- បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ;
- ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច

អភិបាលកិច្ចល្អ គឺជាចំណុចកណ្តាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការ RIA នឹងកាត់បន្ថយការិយាធិបតេយ្យ និងភាពច្រើនហួស/ភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត។

បច្ចុប្បន្នក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ECOSOCC មានតួនាទីជាអ្នកបណ្តុះបណ្តាល ផ្តល់យោបល់ដល់ក្រុមRIAរបស់ក្រសួង ស្ថាប័ន ដែលបច្ចុប្បន្នមានចំនួន១៨ដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងការពារជាតិ ក្រសួងយុត្តធម៌ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៕



## ២- សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃ ការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងកិច្ចពិគ្រោះយោបល់លើសំណើបញ្ញត្តិកម្មពាក់ព័ន្ធក្នុងវិស័យអប់រំ សណ្ឋាគារ អិល ប៊ី អិន អាស៊ាន កំពង់ចាម ថ្ងៃទី១៨-១៩ ខែធ្នូ ឆ្នាំ២០១៧




កាលពីថ្ងៃច័ន្ទ ១កើត ដល់ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៨ និងទី១៩ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារRIAរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រុមការងារRIAរបស់ ECOSOCCនៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តការវាយតម្លៃលើ ផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងកិច្ចពិគ្រោះយោបល់លើសំណើបញ្ញត្តិកម្មពាក់ព័ន្ធក្នុងវិស័យអប់រំ ក្រោមជំនួយបច្ចេកទេសរបស់ADBលេខ៨៨៣៤។



ឯកឧត្តម **សេរី ជំនះ**



ឯកឧត្តម **ម៉ិច សុខា**





ឯកឧត្តម **សេរី ជំនះ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិតិយុត្ត ជាអធិបតីក្នុងអង្គសិក្ខាសាលានេះ ដែលមានវាគ្មិនចំនួន ៥ រូប គឺ ឯកឧត្តម **ម៉ិច សុខា** ឯកឧត្តម **ស៊ិន សេងហុក** ប្រធាននាយកដ្ឋាននីតិកម្មក្រសួងអប់រំ យុវជន និងកីឡា លោក **ម៉ូវ វី** អនុប្រធាននាយកដ្ឋាននីតិកម្មក្រសួងអប់រំ យុវជន និងកីឡា លោក **សុខ សុខសាន្ត** ប្រធានការិយាល័យនៃនាយកដ្ឋានឧត្តមសិក្សា លោក **គង់ សុមីរា** ប្រធាននាយកដ្ឋានឧត្តមសិក្សា។ បន្ទាប់ពីបទបង្ហាញត្រូវបានបញ្ចប់ អង្គសិក្ខាសាលាបានចែកចេញជា ៥ក្រុមពិភាក្សារកធាតុចូល ដើម្បីប្រមូលទិន្នន័យមកវិភាគការវាយតម្លៃបឋមលើផលប៉ះពាល់លើសេចក្តីព្រាងប្រកាសស្តីពីការជ្រើសរើសនិស្សិតចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាក្រោមឳវាទក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីព្រាងប្រកាសស្តីពី ការផ្តល់ ការដកហូត ឬបដិសេធវិញ្ញាបនបត្រ ឬសញ្ញាបត្រដល់អ្នកសិក្សា៕



# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែវិច្ឆិកា ឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,២%ធៀបនឹងខែមុន និងកើនឡើង២,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៨,៤% | ប្រេងសាំង: | +៩,៥% |
| ការដឹកជញ្ជូន: | +៤,៣% | ប្រេងម៉ាស៊ូត: | +៨,៣% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៥% | ត្រីស្រស់: | +៥,២% |
| ម្ហូបអាហារ: | +២% | សាច់គោ: | +២,៥% |
| ទំនិញ និងសេវាកម្មផ្សេងៗ: | +១,៦% | សាច់មាន់: | +១,២% |
| សុខាភិបាល: | +១,៣% | សាច់ជ្រូក: | +១% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +០,៦% | ផ្លែឈើ: | +០,៨% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,២% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ[P] | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ១.៧% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | -០,២% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែ ធ្នូ និងឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. បម្រែបម្រួល និងចលនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

បម្រែបម្រួលសន្ទស្សន៍ថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន




សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(គ្រាគោល ២០០៦)




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | វិច្ឆិកា ២០១៧ | តុលា ២០១៧ | វិច្ឆិកា២០១៦ | *ប្រភេទ* | វិច្ឆិកា ២០១៧ | តុលា ២០១៧ | វិច្ឆិកា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣៥៛/១$ | ៤០៣៧៛/១$ | ៤០៣០៛/១$ | **បាត/ដុល្លារ** | ៣២,៥៧បាត/១$ | ៣៣,២១បាត/១$ | ៣៥,៦៤បាត/១$ |
| **៛/បាត** | ១២៤៛/១បាត | ១២២៛/១បាត | ១១៣៛/១បាត | **ដុង/ដុល្លារ** | ២២៦៧៤ដុង១$ | ២២៧០២ដុង១$ | ២២៦៦៥ដុង/១$ |
| **៛/ដុង** | ០,១៧៨៛/១ដុង | ០,១៧៨៛/១ដុង | ០,១៧៨៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១២៩២,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣២៣,១លានដុល្លារ (*មធ្យមប្រចាំខែ១០៣% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១២៧០,៨ ប៊ីលានរៀល(*មធ្យមប្រចាំខែ ១០៣%នៃផែនការ*) និងចំណូលមូលធនចំនួន ២១,៩ ប៊ីលានរៀល(តាមតួលេខធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ៦,៨% ប៉ុន្តែកើនឡើង២៤,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥-២០១៧ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១០២៦,៨ប៊ីលានរៀល ថយចុះ៨,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២២,៧% ធៀប នឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន២៤៤,១ប៊ីលានរៀល ថយចុះ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២០,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +១,៣%<br>(អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៣០,១%) | ➢កាស៊ីណូ : -៥៧,១% | (+៣,១%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : -៦២,៨% | (-៥១,៩%) |
| ➢ ចំណូលពន្ធដារ: -៤,៣%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (+៥,១%) | ➢ នេសាទ: +២២៦,៣% | (+១២%) |
| | | ➢សម្បទានរ៉ែ: +២២០,៨% | (+១១៣,២%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +១០៤,៣% | (+១៧៨,៤%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +៤,៧% | (+២៩%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: +៣០៥,៦% | (+៥៧,៥%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១៣០០,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣២៥លានដុល្លារ( *មធ្យមប្រចាំខែ ៨៦% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៩៩៦,១ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៩០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៣០៤,៥ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ២០,៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៣២,៤% ធៀបនឹងខែមុនប៉ុន្តែកើនឡើង២៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱន ភាពចំនួន ៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥-២០១៧

(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ៧០៨១៤ប៊ីលានរៀល កើនឡើង០,៨%ធៀបនឹងខែមុន និងកើនឡើង ២៤,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើចរន្ត ២,៥% ប្រាក់បញ្ញើរមានកាលកំណត់និងសន្សំ០,៣% និងប្រាក់បញ្ញើជារូបិយបណ្ណ០,៧% ។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែវិច្ឆិកា ឆ្នាំ២០១៧




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៧% | ១៦,៦% | ១៥,៥% | ១៥,៣% | ១៥,៧% | ១៦,០% | ១៦,៣% | ១៦,៦% | ១៦,៥% | ១៦,៦% | ១៦,៧% | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | ១១,២% | ១១,១% | ១១,៤% | ១១,៦% | ១១,៥% | ១១,៣% | ១១,៤% | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែវិច្ឆិកា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៤៦៣លានដុល្លារ កើនឡើង០,៦%ធៀបនឹងខែមុន និងកើនឡើង២៧,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** : ក្នុងខែនេះមានចំនួន២៦២៦៦ប៊ីលានរៀលកើនឡើង១,៥%ធៀបនឹងខែមុន និងកើនឡើង៣១,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *វិច្ឆិកា២០១៧* | *តុលា២០១៧* | *វិច្ឆិកា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៦៦៧៤៣ | ៦៥៦៧៥ | ៥៥៩៦៣ |
| ក្នុងនោះ ជារៀល | | ១១៩២ | ៨១៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៦៦២៣ | ១២២៩៧ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៨% | ៥,៩៧% | ៦,៨៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៤៤% | ១៤,៥% | ១៧,៣៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤២% | ៤,៤៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥៧% | ១១,៦០% | ១១,៧៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅបាត់ដំបងនិងអង្គរ | ១៨% | ១៨% | ២៣,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៦,១% | ១៦,៣% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពលធម៌

➡ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន១០០,៥៥ពាន់តោន កើនឡើង៥% ធៀបនឹងខែមុន និងកើនឡើង៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៦៩០,២៧GWHមានការថយចុះ១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ១៤៥,៨៥GWH មានការថយចុះ៥៨%ធៀបនឹងខែមុន និងថយចុះ៥៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៦២,១២GWHមានការកើនឡើង៣៦%ធៀបនឹងខែមុន និងមានការកើនឡើង១៣១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤៥១,៥លានដុល្លារ មានការថយចុះ៣៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —វិច្ឆិកា ២០១៧ | ចំនួន—តុលា ២០១៧ | ចំនួន—វិច្ឆិកា ២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១១ | ៤ | ៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៧០១ | ១៦៩៦ | ១៥៦៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៤ | ២២ | ២៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣២ | ១៨ | ១៦ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៨៤,៨ពាន់ម២ថយចុះ៦៨% ធៀបនឹងខែមុន និងថយចុះ៥៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៦១,២លានដុល្លារ ថយចុះ៧៤% ធៀបនឹងខែមុន និងថយចុះ៥៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម២ —វិច្ឆិកា២០១៧ | ពាន់ម២ —តុលា២០១៧ | ពាន់ម២ —វិច្ឆិកា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ១៥០,៧ | ៤៨៣,២ | ៦៣៤,៥ |
| ▪ ឧស្សាហកម្ម | ១៧៨,៥ | ១៧០,៦ | ១៥១,៧ |
| ▪ពាណិជ្ជកម្ម | ៣០,៧ | ៥២៧,៨ | ៦១,៤ |
| ▪ ទេសចរណ៍ | ១៣,៨ | ៣៥,៨ | ៨ |
| ▪ផ្សេងៗ | ០,២ | ០,៥ | ០,៧ |
| អនុញ្ញាតសរុប | ៣៨៤,៨ | ១២១៧,៩ | ៨៥៨,៧ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺឧស្សាហកម្ម៤៦,៣៨% និង លំនៅដ្ឋាន៣៩,១៧% នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់— វិច្ឆិកា ២០១៧ | នាក់—តុលា ២០១៧ | នាក់—វិច្ឆិកា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ៩៧៨ | ១២៨៤ | ១៣០៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៧៣៤៤ | ៩៤២៩ | ១៥៩៣៨ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២២៤៣០ | ៥០១២ | ១៤៩០៥ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៩១៤ | ៤៤១៧ | ១០៣៣ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | វិច្ឆិកា២០១៧ | តុលា២០១៧ | វិច្ឆិកា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤០,៨ | ១២៦,១ | ៥២ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | 0 | 0 | 0 |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤០,៨ (៩,៤) | ១២៦,១ (៧២,៤) | ១២ (៤) |
| វិស័យទេសចរណ៍ | 0 | 0 | ៤០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | 0 | 0 | 0 |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ២០ | ៦ |
| បង្កើតការងារ (ពាន់នាក់) | ៨ | ១០ | ៥,៤ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៩០៩,៨ពាន់តោន កើនឡើង១៦% ធៀបនឹង៩ខែមុន និងកើនឡើង៤២%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

- កំពង់ផែភ្នំពេញ:-៨% (+១២%)
- កំពង់ផែកំពង់សោម:+១៣% (+៤១%)
- កំពង់ផែស្រែអំបិល និងកោះកុង:-២៥% (+១៩៨%)
- កំពង់ផែឧកញ៉ាម៉ុង: +២៤៨% (+១៣៣%)

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៦,១ | -២% | ២៦% |
| ក្នុងនោះទទួល | ២,២ | -១១% | ១៦% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០៥,៩ | ១៥% | 0% |
| ក្នុងនោះទទួល | ៥០,១ | -១០% | ១២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២០៩៤,១ | ៤% | -១៧% |
| ក្នុងនោះហៅចូល | ៦២៤,៣ | ២% | -១៨% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥៥៩១,២ | -៥% | -៤៥% |
| ក្នុងនោះហៅចូល | ៥៥០៣,៨ | -៦% | -៤៥% |

### ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៦,៣ | ៥៨% | ១៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥៨,១ | ២៥% | ៣៨% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧៣៩,៨ | ១៩% | ២៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៤៦,៣ | -0,៤% | ១៨% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៥៧០,៥ | ៣៧% | ១៩% |
| ✓ តាមផ្លូវអាកាស | ៣២៤,៩ | ២១% | ២០% |
| ✓ តាមផ្លូវគោក និងទឹក | ២៤៥,៦ | ៦៦% | ១៨% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនា ខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួន៤៧០៧,៧ប៊ីលានរៀល (ស្មើនឹង១១៧៦,៧លានដុល្លារ ស.រ.អា.)កើនឡើង២,៣% ធៀបនឹងខែមុន និងកើនឡើង៨% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៩,៤% | +១៤,៤% | រថយន្តសរុប (ប៊ី.ល.រ) | +៩,៦% | +៥៤,៩% |
| ប្រេងម៉ាស៊ូត | +២,៣% | +២% | រថយន្តសរុប (គ្រឿង) | -៥,៧% | +៣៤% |
| ឧស្ម័ន | -៧,៣% | ០% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៤,៥% | +៨៩,៨% |
| អគ្គិសនីនាំចូល | +៤៧% | +៧៧% | ម៉ូតូ (គ្រឿង) | +៤៥,៦% | +២៥,៣% |
| ដែកសំណង់ | -៥,៣% | +៤,៨% | អង្ករ | -២៦% | +៥៩០% |
| ស៊ីម៉ង់ត៍ | +៦៨,៨% | +៤២,៩% | ផ្លែឈើនិងបន្លែ | -១៦,៥% | -៩,៩% |
| គ្រឿងអេឡិចត្រូនិក | -១៥,២% | | ជីនិងថ្នាំកសិកម្ម | -៣៨,១% | -១២,៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +០,៣% | +១៣,៣% |

➡ **ការនាំចេញ** ខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួន**៣២១៣,៦**ប៊ីលានរៀល ស្មើនឹង៨០៣,៤លានដុល្លារស.រ.អា(៦៨% នៃការនាំចូល)ថយចុះ១២,៨%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៩,១% | +២៩០,២% | ផលិតផលនេសាទ | -១៣,១% | +៤៦,២% |
| វាយនភណ្ឌនិងស្បែកជើង | -១៧,៧% | -៤,៤% | កៅស៊ូ | +២៩,៨% | +១៤,៨% |
| អង្ករ | +៨% | +២៦,៤% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +០,៦% | +៩,៥% | |
| ២ | ថ្លៃប្រេងម៉ាស៊ូត | +០,១% | +៨,៥% | |
| ៣ | សំណង់អនុញ្ញាតិឲ្យសាងសង់(ពាន់ ម²) | -៦៨% | -៥៥% | |

## ៧) សេចក្តីសន្និដ្ឋាន

១)សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានការកើនឡើងតិចតួចក្នុងខែវិច្ឆិកានេះ (កើន0,២% ធៀបនឹងខែមុន និងកើន២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន) ហើយជារួម អត្រាអតិផរណានឹងមានកម្រិតទាប ក្នុងឆ្នាំ២០១៧ (ជុំវិញ ៣%)។ ក្នុងនោះ យើងសង្កេតឃើញថា ម្ហូបអាហារក៏មានការឡើងថ្លៃទាបដែរ ខុសពីឆ្នាំមុនៗ ដែលអតិផរណាម្ហូបអាហារតែងមានអត្រាខ្ពស់។ យ៉ាងណាមិញ មានមុខទំនិញមួយចំនួន មានការឡើងថ្លៃគួរឲ្យចាប់អារម្មណ៍ ដូចជា ត្រីស្រស់ បន្លែ និងប្រេងឥន្ធនៈ។

២)ទីផ្សារទំនិញមួយចំនួន ដែលការប្រកួតប្រជែងមានកម្រិតទាប ដូចជា ប្រេងឥន្ធនៈ ឈ្នួលផ្ទះ សេវាប្រមូលសម្រាម ទឹកស្អាតជាដើម ការគ្រប់គ្រងថ្លៃពីសំណាក់រាជរដ្ឋាភិបាលជាការចាំបាច់ ដើម្បីជៀសវាងអនាធិបតេយ្យនៃអ្នកផ្គត់ផ្គង់ និងឥទ្ធិពលអវិជ្ជមានលើស្មារតីនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ។

៣)ខ្វះការត្រួតពិនិត្យលើការផ្សព្វផ្សាយពាណិជ្ជកម្ម ជាពិសេសទាក់ទងនឹងការផ្សព្វផ្សាយឱសថមួយចំនួន ដូចជាឱសថបុរាណ អាហារបំប៉ន ឬទំនិញសុខភាពមានលក្ខណៈពាណិជ្ជកម្មផ្សេងៗទៀត ដែលអួតអាងអំពីប្រសិទ្ធភាពព្យាបាល ឬឥទ្ធិពល លើសពីលក្ខណៈជាក់ស្តែងនៃទំនិញ ដើម្បីដាក់ថ្លៃខ្ពស់ ឬអូសទាញអតិថិជន ៕

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១២/១៧<br>ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីក្រុងពាលី និងពិធីសូត្រមន្តចម្រើនសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប។ |
| ២ | ០៣/១២/១៧<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបួងសួងចម្រើនសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប។ |
| ៣ | ០៥/១២/១៧<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទមហាសន្និបាតវិសាមញ្ញកាយរឹទ្ធិជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ៤ | ០៥/១២/១៧<br>ម៉ោង១១:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុវិជ្ជានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/១២/១៧<br>ម៉ោង១៦:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **យឹម ណុលសន** និងឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៧/១២/១៧<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៩ និងទិវាជនពិការអន្តរជាតិលើកទី៣៥ ក្រោមប្រធានបទ "ធ្វើឲ្យមានភាពរឹងមាំស្របនឹងសង្គមមួយមានសន្តិភាពសម្រាប់ទាំងអស់គ្នា!" ក្រោមអធិបតីភាព សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ |
| ៧ | ០៧/១២/១៧<br>ម៉ោង១៥:០០នាទី | ចូលរួមជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីឲ្យក្រុមហ៊ុនភាគីចិន(ក្រុមហ៊ុនយូណាន) និងក្រុមហ៊ុនភាគីចិនអគារថ្មី(អគារខាងត្បូង) នៅបន្តថែទាំជួសជុលប្រព័ន្ធអគ្គិសនី ប្រព័ន្ធមេកានិកអគារ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសកម្ពុជាបន្ថែមទៀតរយៈពេលបីឆ្នាំ និងស្នើសុំសម្ភារៈមួយចំនួនដើម្បីងាយស្រួលដល់មន្ត្រីបច្ចេកទេសកម្ពុជាថែរៈថែទាំ និងជួសជុលប្រព័ន្ធបច្ចេកទេសក្នុងអគារទាំងពីរនេះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **០៩/១២/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរការជ្រើសតាំង សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីជា "ឯកអគ្គរាជទូតសុច្ឆន្ទៈទេសចរណ៍អន្តរជាតិ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព" និងការប្រគល់ពានរង្វាន់ដល់"រាជធានីភ្នំពេញ៖ ជារាជធានីនៃទេសចរណ៍ និងវប្បធម៌ពិភពលោកសម្រាប់ឆ្នាំ២០១៧-២០១៨" របស់ក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុប នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | **០៩/១២/១៧ ម៉ោង១០:០០នាទី** | អមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម **អ៊ឹម សិទ្ធិ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅគេហដ្ឋាននៃសព។ |
| ១០ | **១១/១២/១៧ ម៉ោង១៤:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០១៧ និងទិសដៅការ ងារឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្រសួងបរិស្ថាន។ |
| ១១ | **១២/១២/១៧ ម៉ោង១៥:០០នាទី** | ទទួលជួបពិភាក្សាការងារជាមួយលោក **Eric DELOBEL CEO** ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **១២/១២/១៧ ម៉ោង១៧:០០នាទី** | ទទួលជួបពិភាក្សាការងារជាមួយលោក **Li Chengwei** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **១៣/១២/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្ថានីយអ្នកដំណើរក្នុងស្រុកថ្មី និងកន្លែងថ្មីសម្រាប់ទទួលការមកដល់នៃអ្នកដំណើរអន្តរជាតិ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ១៤ | **១៣/១២/១៧ ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ឌុយ ឆៅ** និងឯកឧត្តម **លី គឹមសុខ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **១៥/១២/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ប្រាក់រង្វាន់រាជរដ្ឋាភិបាលជូនជ័យលាភីមេដាយមាស ក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៦ | **១៥/១២/១៧ ម៉ោង១៥:០០នាទី** | ចូលរួមក្នុងកិច្ចប្រជុំ គណៈកម្មាធិការត្រួតពិនិត្យគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមការងារទទួលចង្កោមការងារត្រួតពិនិត្យនិងសន្តិសុខ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ូ ភិរិន្ទ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការត្រួតពិនិត្យគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារទទួលបន្ទុកចង្កោមការងារត្រួតពិនិត្យនិងសន្តិសុខ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២០/១២/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ២០១៧-២០២៦។<br>២-សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២១/១២/១៧ ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ២០១៧-២០២៦។<br>២-សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **២១/១២/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | **២២/១២/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីឆ្នាំ២០១៧-២០២៦។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| | | ២-សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។<br>៣-បញ្ហាផ្សេងៗ៖<br>សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២១ | **២៧/១២/១៧**<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតនៅតំបន់វត្តអង្គគ្រគៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រៃស្ពឺ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ។ |
| ២២ | **២៨/១២/១៧**<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | **២៨/១២/១៧**<br>**ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្រសួងពាណិជ្ជកម្ម។ |
| ២៤ | **៣០/១២/១៧**<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានាវិទ្យាល័យសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ពោធិ៍អណ្តែតដើមឬស ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាល័យសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ពោធិ៍អណ្តែតដើមឬស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in